

# កម្មវិធី P-EBT រដូវក្តៅបានមកដល់ហើយ!

## តើកម្មវិធី P-EBT រដូវក្តៅគឺជាកម្មវិធីអ្វី?

កម្មវិធី EBT ឬ P-EBT សម្រាប់ពេលរោគរាតត្បាតផ្តល់ជូនអត្ថប្រយោជន៍អាហារដល់កុមារ ដើម្បីជំនួសថ្លៃអាហារដោយសារតែសេវាបម្រើអាហារមានកំណត់នៅសាលារៀន និងមណ្ឌលថែទាំកុមារដោយសារវិបត្តិជំងឺ COVID-19។ យើងបានទទួលការយល់ព្រមពីសហព័ន្ធដើម្បីពន្យារពេលកម្មវិធី P-EBT រហូតដល់ច្រើនខែនារដូវក្តៅ។

## តើអ្នកណាខ្លះមានសិទ្ធិទទួលបាន?

កុមារអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយស្វ័យប្រវត្តិក្នុងការទទួលបានកម្មវិធី P-EBT រដូវក្តៅប្រសិនបើពួកគេបំពេញបានតាមលក្ខខណ្ឌមួយដូចខាងក្រោម៖

- ពួកគេមានសិទ្ធិទទួលបានអាហារសាលាដោយកតគិតថ្លៃ ឬបញ្ចុះតម្លៃក្នុងឆ្នាំសិក្សា 2020-21 ហើយបានចុះឈ្មោះចូលរៀននៅចុងឆ្នាំសិក្សានៅសាលាវ៉ាស៊ីនតោនដែលជាធម្មតាចូលរួមក្នុង National School Lunch Program (កម្មវិធីអាហារថ្ងៃត្រង់របស់សាលារដ្ឋ) ឬ School Breakfast Program (កម្មវិធីអាហារពេលព្រឹករបស់សាលា)។
- កុមារអាយុក្រោម 6 ឆ្នាំដែលជាសមាជិកគ្រួសារដែលកំពុងចូលរួមយ៉ាងសកម្មក្នុងកម្មវិធីជំនួយ Basic Food (ស្បៀងអាហារមូលដ្ឋាន) របស់រដ្ឋវ៉ាស៊ីនតោនគ្រប់ពេលវេលាចន្លោះពីខែមិថុនា កក្កដា ឬសីហា ឆ្នាំ 2021។

## តើគ្រួសារអាចទទួលបានកម្មវិធី P-EBT រដូវក្តៅយ៉ាងដូចម្តេច?

- គ្រួសារដែលមានបុត្រធីតាបំពេញបានតាមលក្ខខណ្ឌនៃសិទ្ធិទទួលបានដែលបានរៀបរាប់ខាងលើមិនចាំបាច់ធ្វើអ្វីទេ! អត្ថប្រយោជន៍នៃកម្មវិធី P-EBT រដូវក្តៅនឹងត្រូវបានចេញដោយស្វ័យប្រវត្តិ។
- គ្រួសារដែលមិនទាន់បំពេញបានតាមលក្ខខណ្ឌនៃសិទ្ធិទទួលបានដែលបានរៀបរាប់ខាងលើនៅតែអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី P-EBT រដូវក្តៅប្រសិនបើពួកគេធ្វើដូចខាងក្រោមមុនថ្ងៃទី 31 ខែសីហា ឆ្នាំ 2021៖
    - កុមារនៅសាលារៀន - ប្រសិនបើកូនរបស់អ្នកបានចុះឈ្មោះចូលរៀននៅសាលាដែលផ្តល់ជូនកម្មវិធី NSLP នៅខែមិថុនា ឆ្នាំ 2021 សូមដាក់ពាក្យសុំអាហារកតគិតថ្លៃ ឬបញ្ចុះតម្លៃដើម្បីសុំការអនុម័តយល់ព្រមពីសាលារបស់កូនអ្នក។ ប្រសិនបើកូនរបស់អ្នកត្រូវបានអនុញ្ញាតឱ្យទទួលទានអាហារដោយកតគិតថ្លៃ ឬបញ្ចុះតម្លៃ អ្នកនឹងទទួលបានអត្ថប្រយោជន៍នៃកម្មវិធី P-EBT រដូវក្តៅ។
    - កុមារអាយុក្រោម 6 ឆ្នាំ - សូមដាក់ពាក្យស្នើសុំ Basic Food (អាហារមូលដ្ឋាន) នៅលើគេហទំព័រ៖ Ç www.WashingtonConnection.org ឬហៅទូរសព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាអតិថិជន DSHS តាមលេខ 877-501-2233 ដើម្បីធ្វើការសម្ភាសន៍។

## តើគ្រួសារនឹងទទួលបានប៉ុន្មាន?

កុមារដែលមានសិទ្ធិទទួលបានកម្មវិធី P-EBT រដូវក្តៅនឹងទទួលបានប្រាក់ឧបត្ថម្ភចំនួនសរុប $375 ដុល្លារម្តង ដើម្បីទូទាត់ការចំណាយនៅរដូវក្តៅសម្រាប់ ខែកក្កដា និងសីហា ឆ្នាំ 2021។

## តើគ្រួសារនឹងទទួលបានកាត P-EBT ថ្មីជារៀងរាល់ខែដែរឬទេ?

ទេ គ្រួសារគួររក្សាទុកកាត P-EBT សម្រាប់កូនម្នាក់ៗ។ ដោយមានការអនុម័តយល់ព្រមពីសហព័ន្ធ យើងអាចបញ្ចូលទឹកប្រាក់ទៅក្នុងកាតនេះ ប្រសិនបើភាពអាសន្នសុខភាពសាធារណៈដោយសារជំងឺ COVID-19 នៅតែបន្ត។

## សូមចូលទៅកាន់គេហទំព័រ dshs.wa.gov/PEBT ដើម្បីស្វែងយល់បន្ថែម!

ប្រសិនបើអ្នកត្រូវការព័ត៌មាននេះជាភាសាផ្សេង សូមចូលទៅកាន់គេហទំព័រនេះ ឬហៅទូរសព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនង P-EBT តាមរយៈលេខ **833-518-0282**។

គ្រួសារត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងកម្មវិធីអាហាររបស់សាលាគឺ កម្មវិធីយកអាហារហើយទៅ (Grab-n-Go) ទោះបីជាពួកគេមានអត្ថប្រយោជន៍នៃកម្មវិធី P-EBT ក៏ដោយ។

*ស្ថាប័ននេះគឺជានិយោជកដែលផ្តល់ឱកាសស្មើភាពគ្នា។*

Washington State Department of Social & Health Services

*Transforming lives*